# សុន្ទរកថា
# របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសទិវាអនុស្សាវរីយ៍
# ខួបលើកទី ១០ របស់មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា
# នៅពហុកីឡាដ្ឋានជាតិអូឡាំពិក
# ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៦

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ*

*- បងប្អូនមន្ត្រីរាជការ ជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗ សិស្សានុសិស្ស និងជនពិការទាំងអស់ជាទីស្រឡាញ់*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដោយបានមកចូលរួមក្នុង ***ទិវាអនុស្សាវរីយ៍ខួបលើកទី ១០ នៃមជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា***។ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ សូមអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះជោគជ័យដែល ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** ទទួលបានក្នុងរយៈពេល ១០ ឆ្នាំ កន្លងទៅនេះ។

ខ្ញុំនៅចាំបានថា កាលពី ១០ ឆ្នាំ កន្លងទៅ នាថ្ងៃ ៥ ខែ ឧសភា ឆ្នាំ ១៩៩៧ ខ្ញុំបានមកចូលរួមក្នុងពិធីសម្ពោធបើកឱ្យ

ដំណើរការនូវ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា***។ រហូតមកដល់ពេលនេះ រយៈពេល ១០ ឆ្នាំ បានកន្លងផុតទៅ ប៉ុន្តែមជ្ឈមណ្ឌលជាតិនេះបានរក្សានិរន្តភាព នៃសកម្មភាពរបស់ខ្លួន ព្រមទាំងបង្កើតបាននូវស្នាដៃជាច្រើន រួមចំណែកក្នុងការអភិវឌ្ឍន៍ជនពិការទាំងស្មារតីនិងសម្ភារៈ។ ប្រការដែលគួរឱ្យចាប់អារម្មណ៍ក្នុងចំណោមថ្នាក់ដឹកនាំនិងបុគ្គលិកនៃមជ្ឈមណ្ឌលជាតិជនពិការស្ទើរតែទាំងអស់ជាជនពិការ ប៉ុន្តែបានបង្ហាញនូវសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំគ្រប់គ្រង***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** នេះឱ្យដំណើរការប្រកបដោយតម្លាភាពទទួលបាន នូវជោគជ័យ និងជាទីទំនុកចិត្តរបស់អ្នកផ្តល់ជំនួយនានា ដែលបានឧបត្ថម្ភគាំទ្រដល់មជ្ឈមណ្ឌល។ ជាមួយគ្នានេះ ខ្ញុំមានការពេញចិត្តចំពោះអ្នកដឹកនាំចលនាជួយខ្លួនឯងរបស់ជនពិការដែលជាជនពិការផ្ទាល់ដូចលោក ***យី ទាសនា*** និងអស់លោក លោកស្រី ជាសមាជិក សមាជិការបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិក ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** យើង។ ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមកោតសរសើរចំពោះ ***ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា*** និង***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា***

ដែលបានរៀបចំពិធីនេះ ដើម្បីបង្កឱកាសឱ្យខ្ញុំបានមកជួបសំណេះសំណាល និងបានសាកសួរសុខទុក្ខបងប្អូនជនពិការ។

ជាការពិត ជោគជ័យទាំងអស់នេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការតស៊ូយ៉ាងខ្លាំងក្លារបស់បងប្អូនពិការ ក្នុងការលើកកំពស់ជីវភាពរស់នៅផ្ទាល់ខ្លួន ព្រមទាំងគ្រួសារតាមរយៈការធ្វើការងារតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន និងការបើកអាជីវកម្មផ្ទាល់ខ្លួន និងជាសមូហភាព។ ល។ ជោគជ័យនេះក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញពីការចូលរួមរបស់ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** ក្នុងការអនុវត្តន៍កម្មវិធីនៃ***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាលសំដៅ *«ជំរុញកំណើនសេដ្ឋកិច្ច» «បង្កើត **ការងារ** ជូនពលករកម្ពុជា» «លើកស្ទួយ **សមធម៌** ក្នុងសង្គម»* និង *«ពង្រឹង **ប្រសិទ្ធភាព** ក្នុងវិស័យសាធារណៈ»*។ ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសអ្នកផ្តល់ជំនួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលផ្តល់ការគាំទ្រដល់ដំណើរការរបស់ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** ប្រកបដោយជោគជ័យនារយៈកាលកន្លងមក ក៏ដូចនាពេលបច្ចុប្បន្ននេះ។ រាជ-

រដ្ឋាភិបាលកម្ពុជាសូមចាត់ទុកថា ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ គឺជាដៃគូដ៏មានប្រសិទ្ធភាពក្នុងការកសាងប្រទេសជាតិ។ ក្នុងទស្សនៈនេះហើយដែលរាជរដ្ឋាភិបាលបានលើកទឹកចិត្តតាមគ្រប់រូបភាព ដល់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលកំពុងធ្វើសកម្មភាពបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទាំងប្រទេស។ រាជរដ្ឋាភិបាលសូមស្វាគមន៍ និងលើកទឹកចិត្តដល់ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ក្នុងដំណើរការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច- សង្គមកិច្ចនឹងគាំទ្រការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

*- អង្គមីទីញទាំងមូលជាមេត្រី*

រាជរដ្ឋាភិបាលកម្ពុជាជានិច្ចកាលតែងតែយកចិត្តទុកដាក់ក្នុងការធ្វើសមាហរណកម្មជនពិការទៅក្នុងសង្គម ធ្វើយ៉ាងណាឱ្យបងប្អូនពិការទទួលបានរាល់តម្រូវការចាំបាច់នានា របស់មនុស្ស ជាពិសេសគឺធានាការគោរពសិទ្ធិជាមូលដ្ឋានរបស់បងប្អូន ដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ សិទ្ធិធ្វើការងារនិងសិទ្ធិចេញចូលតាមទីសាធារណៈនានា។ល។ គឺផ្តល់ឱកាសដល់បងប្អូនពិការ បានចូលរួមពេញលេញនិងស្មើ

ភាពទៅក្នុងសង្គម សំដៅកសាងសង្គមមួយសម្រាប់ទាំងអស់គ្នា សង្គមមួយគ្មានឧបសគ្គ គ្មានការរើសអើង សង្គមមួយផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន ស្របទៅតាម « *ក្របខ័ណ្ឌការងារនៃសហស្សវត្សរ៍ប៊ីវ៉ាកូ* (BIWAKO) »*សកម្មភាពឆ្ពោះទៅរកការធ្វើសមាហរណកម្មជនពិការនៅក្នុងសង្គមដែលមានសិទ្ធិសេរីភាពស្មើគ្នា និងគ្មានការរារាំង* ឆ្នាំ ២០០៣-២០១២/។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានចុះហត្ថលេខាលើ «*កិច្ចព្រមព្រៀងនៃសេចក្តីប្រកាសស្តីពីទសវត្សរ៍នៃជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក*» ដើម្បីរួមចំណែកជួយជនពិការឱ្យបានចូលរួមក្នុងសង្គមស្មើភាពគ្នាជាមួយគ្រប់ជនដទៃ/។

ជាមួយគ្នានេះដែរ ខ្ញុំសូមយកឱកាសដ៏មហោឡារិកនេះ ផ្តាំផ្ញើនូវការសួរសុខទុក្ខ និងសេចក្តីនឹករលឹកដល់បងប្អូនពិការទាំងអស់ /។ ជាថ្មីម្តងទៀត ខ្ញុំសូមប្រកាសទទួលស្គាល់នូវការតស៊ូយ៉ាងសកម្ម និងការប្តេជ្ញារបស់បងប្អូនជនពិការដើម្បីបង្ហាញថាខ្លួនមានសមត្ថភាពនិងឆន្ទៈក្នុងការចូលរួមចំណែកក្នុងគ្រប់ផ្នែកជីវិតរស់នៅ រួមមានៈ សេដ្ឋកិច្ចសង្គម នយោបាយ និងវប្បធម៌ ទោះបីជាមានឧបសគ្គរារាំងជាច្រើនក៏ដោយ /។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមប្រកាស និងប្តេជ្ញាចិត្តខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីលុបបំបាត់នូវឧបសគ្គ និងបន្តជំរុញឱ្យបងប្អូនពិការ និងក្រុមគ្រួសារអាចចូលរួម និងប្រើប្រាស់នូវសក្តានុពល និងសមត្ថភាព ដែលខ្លួនមានចូលរួមចំណែក ***អភិវឌ្ឍគ្រួសារ សហគមន៍ និងសង្គមជាតិ***។

ច្បាស់ណាស់ថា យើងមិនអាចបំភ្លេចចោលជនពិការទេ ពីព្រោះអ្នកទាំងនោះមួយផ្នែកពិការដោយសារបុព្វហេតុជាតិ និងមាតុភូមិហើយមួយផ្នែកទៀត គេគ្រាន់តែជាអ្នករងគ្រោះដោយសង្គ្រាម ដោយគ្រាប់មីន ដោយជម្ងឺ ដោយគ្រោះថ្នាក់ ឬ ដោយមកពីកំណើតតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ពួកគេកំពុងស្ថិតនៅក្នុងស្ថានភាពងាយនឹងរងគ្រោះបន្ថែមទៀតផង ដោយសារភាពក្រីក្រ និងមានឱកាសតិចជាងគេបំផុតក្នុងការទទួលការងារ និងប្រកបមុខរបររកស៊ី។ អ្នកដែលរងភាពអយុត្តិធម៌ជាងគេពីព្រហ្មលិខិត គឺជនពិការ។ ជាការពិត សេដ្ឋកិច្ចទីផ្សារមិនដែលអនុគ្រោះ ឬ យោគយល់ដល់ជនពិការទេ ពីព្រោះសេដ្ឋកិច្ចទីផ្សារពិតប្រាកដតម្រូវឱ្យមាន ***ការប្រកួតប្រជែង*** ដោយ

យុត្តិធម៌ ប៉ុន្តែមិនបានគិតឱ្យដិតដល់នូវបញ្ហា ***សមធម៌*** នៅក្នុងសង្គមនោះទេ /។

ដូចដែលឯកឧត្តម ***អ៊ិត សំហេង*** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរាយការណ៍ក្នុងរយៈកាលកន្លងទៅ ក៏ដូចជាបច្ចុប្បន្នមានជនពិការច្រើនណាស់ ដែលបានរួមចំណែកផលិតផ្គត់ផ្គង់បំពេញការងារបម្រើដល់សង្គមបានល្អដូចគ្នា ឬ លើសពីជនធម្មតាក៏មាន /។ ទេពកោសល្យនៃជនពិការកម្ពុជា ក្នុងវិស័យសិល្បៈ វប្បធម៌ សិប្បកម្មក៏មានមិនតិចដែរ ហើយនោះក៏សុទ្ធតែជាស្នាដៃ ដែលមនុស្សធម្មតាជាច្រើនមិនអាចធ្វើបានក៏មាន ដូចផលិតផលតាំងពិពណ៌ខាងមុខវេទិកានេះស្រាប់ /។ កីឡាករជនពិការកម្ពុជាបានឡើងលើឆាកប្រកួតអន្តរជាតិ ហើយក៏បានពាំនាំមកវិញនូវមេដាយ និងកិត្តិយសលើសពីការស្មានផងដែរ /។ តើការជាក់ស្តែងនេះអាចឱ្យយើងយល់បានដូចម្តេចទៅ? ជាការពិតភាពពិការខាងរាងកាយមិនមែនជាមូលហេតុ មិនមែនជាលេសសម្រាប់ឱ្យសង្គមត្រូវទាត់គេចោលនោះទេ /។ ប្រការដែលចាំបាច់ គឺសង្គមត្រូវយល់ឱ្យបានត្រឹមត្រូវថា ឱ្យតែគេអាចរំដោះ

ខ្លួនពីភាពពិការខាងផ្លូវចិត្តបាន នោះគេនឹងលែងពិការទៀតហើយ /។ ខ្ញុំយល់ថា មនុស្សណាក៏ដោយឱ្យតែពិការផ្លូវចិត្តហើយនោះ កាយពិការក្តី មិនពិការក្តី គេទាំងនោះមិនអាចធ្វើអ្វីស្មើនឹងជនពិការ ដែលបានរំដោះខ្លួនចេញពីភាពពិការផ្លូវចិត្តរបស់ខ្លួនបានឡើយ /។ ប្រការនេះ ខ្ញុំចង់បញ្ជាក់ឱ្យអង្គមីទ្ទីញជ្រាបថា មុនបង្អស់ត្រូវខិតខំជួយរំដោះភាពពិការផ្លូវចិត្តចេញពីជនពិការរបស់យើង ហើយនោះគឺជាសេចក្តីត្រូវការដំបូងបំផុតពីបងប្អូនពិការជាទីស្រឡាញ់របស់យើង/។

- ***អង្គមីទ្ទីញទាំងមូលជាទីមេត្រី***

ខ្ញុំសូមសំណូមពរឱ្យអង្គមីទ្ទីញទាំងមូល គប្បីយកចិត្តទុកដាក់ពិនិត្យពិចារណាដើម្បីធ្វើយ៉ាងណាឱ្យជនពិការកម្ពុជារំដោះបានភាពពិការរបស់ខ្លួន ដោយឱ្យសង្គមមើលឃើញពីសមត្ថភាពជាជាងការមើលឃើញ ពីពិការភាព និងទប់ស្កាត់មិនឱ្យកើតមានថែមទៀតនូវគ្រោះពិការភាព/។ ជាការពិត ខ្ញុំចង់និយាយដល់រាល់ការលើកទឹកចិត្តពីសង្គមទាំងមូលចំពោះជនពិការ ធ្វើឱ្យជនពិការលែងមានអារម្មណ៍ឃ្លាតឆ្ងាយពីសង្គម ឬ យល់ថាខ្លួនលែងមានផលប្រយោជន៍អ្វីដល់សង្គម និងគ្រួសារទៀត

ហើយ។ ប្រាកដណាស់ថា ចង់ធ្វើបាន ដូច្នេះគឺសង្គមទេ ដែលត្រូវឆ្លុះបង្ហាញឱ្យជនពិការម្នាក់ៗយល់បានថា សង្គម និងរូបគេគឺស្ថិតនៅជាមួយគ្នា និងគ្មានការបែងចែក។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលក្តី ក្រសួងស្ថាប័នទាំងអស់ក្តី អង្គការមិនមែនរដ្ឋាភិបាលក្តី គប្បីពិចារណាថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យសង្គមទាំងមូលផ្តល់ឱកាសឱ្យបានច្រើនសម្រាប់ជនពិការ។

ការមើលឃើញសមត្ថភាពជនពិការនេះ គឺជាគំនិតទូទៅសម្រាប់គ្រប់ៗគ្នា ប៉ុន្តែសម្រាប់ជនពិការអត្ថន័យនេះ មានចរិតពិសេសជាងសម្រាប់មនុស្សធម្មតា។ បើយើងអាចផ្តល់ជំនាញឱ្យដល់ជនពិការបាន ហើយវាមិនមែនមានន័យថា អាចបញ្ចប់ត្រឹមនេះបានទេ។ ជាក់ស្តែងនៅក្នុងសេដ្ឋកិច្ចទីផ្សារ ការបណ្តុះបណ្តាលរួចផ្តល់វិញ្ញាបនប័ត្រដល់ជនពិការ មិនខុសពីត្រឹមបានជួយឱ្យជនពិការមានវិញ្ញាបនប័ត្រតាំងនៅផ្ទះតែប៉ុណ្ណោះ មានន័យថា ទោះបីមានវិញ្ញាបនប័ត្រ ក៏គេមិនអាចរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតបានដែរ។ ដូចខ្ញុំបានគូសបញ្ជាក់ពីខាងលើ សេដ្ឋកិច្ចទីផ្សារមិនដែលយោគយល់ ឬ អនុគ្រោះដល់ជនពិការនោះទេ ប៉ុន្តែយើងក៏មិនអាចប្រឆាំងនឹងក្រឹត្យក្រមសេដ្ឋកិច្ច

ទីផ្សារ ដោយចាប់ទីផ្សារឱ្យធ្វើតាមអំណាចរបស់យើងបានឡើយ ដូច្នេះយើងគប្បីមានការសិក្សាច្បាស់លាស់ថា ក្រោយពីបានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ ហើយនោះយើងចាំបាច់ត្រូវគិតគូរឱ្យបានហ្មត់ចត់ថា តើត្រូវធ្វើយ៉ាងណាឱ្យគេអាចចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារបានដូចគេទាំងពួង ? មានន័យថា ជនពិការដែលត្រូវបានបណ្តុះបណ្តាល គឺត្រូវឈរស្មើនឹងអ្នកដទៃ ហើយប្រណាំងប្រជែងគ្នាដោយសេរី ដើម្បីចិញ្ចឹមជីវិតបានពីសេដ្ឋកិច្ចទីផ្សារនេះ ។ ខ្ញុំសូមសំណូមពរដល់ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា***និងគ្រប់កន្លែងបណ្តុះបណ្តាលទាំងអស់ រាប់ទាំងរបស់រដ្ឋ របស់អង្គការមិនមែនរដ្ឋាភិបាល សុំយកចិត្តទុកដាក់ពិនិត្យពិចារណាជាថ្មី ហើយរួមគ្នាផ្តល់ឱកាសឱ្យជនពិការ ។

តាមតួលេខនៃការសិក្សាសេដ្ឋកិច្ច- សង្គមឆ្នាំ ១៩៩៧ បង្ហាញថា មានជនពិការកម្ពុជាចំនួនប្រមាណ ២០០.០០០ នាក់ ។ ចំនួននេះមាន ៣៣% ពិការដោយជម្ងឺ ២៥% ពិការមកពីកំណើត ២០% ពិការដោយសង្គ្រាម និងគ្រាប់មីន និងប្រមាណ ១៣% ពិការដោយគ្រោះថ្នាក់ និងឧប្បទ្ទវហេតុផ្សេងៗ ។ ដើម្បី

ទប់ស្កាត់មិនឱ្យកើតថែមទៀតនូវគ្រោះពិការភាពនេះ ខ្ញុំសូមឱ្យក្រសួងសុខាភិបាលពង្រឹងកម្មវិធីបង្ការពិការភាពដល់ប្រជាពលរដ្ឋគ្រប់រូប តាមរយៈការថែទាំសុខភាព ក្នុងពេលមានគភ៌ ការតាមដាន និងការវិនិច្ឆ័យរោគ ដែលនាំឱ្យមានពិការភាពឱ្យបានទាន់ពេលវេលា ការផ្តល់ថ្នាំបង្ការជម្ងឺដែលនាំឱ្យមានភាពពិការ ការព្យាបាលតាមវិធីវេជ្ជសាស្ត្រ និងការអប់រំកាយសម្បទាឡើងវិញឱ្យទាន់ពេលវេលា ជាពិសេសបញ្ចូលបច្ចេកទេសព្យាបាលដោយចលនា និងព្យាបាលសតិបញ្ញានៅតាមសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនានា ហើយបញ្ចូលផ្នែកនេះឱ្យមានគ្រប់មន្ទីរពេទ្យដើម្បីព្យាបាលអ្នកជម្ងឺកុំឱ្យធ្លាក់ខ្លួនពិការ។

ចាប់តាំងពីដើមឆ្នាំ ១៩៩៩ យើងបានទទួលនូវសុខសន្តិភាពពេញលេញនៅទូទាំងប្រទេស។ នេះគឺជាកត្តាខ្លាំងមួយដែលរារាំងមូលហេតុពិការ ដោយសារសង្គ្រាមឱ្យថយចុះយ៉ាងខ្លាំង ប៉ុន្តែនៅមានគ្រាប់មីនច្រើនទៀត ដែលអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការដោយសារមីន និងប្រតិបត្តិករដោះមីនទាំងអស់ ត្រូវបន្តបេសកកម្មឱ្យបានខ្លាំងក្លាថែមទៀត ដើម្បីកាត់បន្ថយនៃមូលហេតុពិការភាព

និងរំដោះដីជូនប្រជាពលរដ្ឋ នៅតាមមូលដ្ឋានឱ្យប្រកបរបរកសិកម្មសម្រាប់លើកស្ទួយជីវភាពរស់នៅឱ្យបានល្អ ។ ក្នុងស្មារតីនេះ ក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវរួមសហការពេញទំហឹង ដើម្បីធានាសន្តិសុខ សុវត្ថិភាព ការងារសណ្តាប់ធ្នាប់សង្គម ចរាចរ ។ល។ ដើម្បីរារាំងកុំឱ្យមានពិការភាពកើតឡើងថែមទៀត ។

*- អង្គមីទ្ធីញទាំងមូលជាទីមេត្រី*

បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងតែគិតគូរឱ្យមានការផ្លាស់ប្តូរទស្សនៈពិការភាព ដែលផ្អែកលើសប្បុរសធម៌ឱ្យទៅជាទស្សនៈពិការភាព ដែលផ្អែកលើសិទ្ធិមនុស្សវិញ ពីព្រោះការពឹងផ្អែកលើជំនួយមនុស្សធម៌មិនអាចធានានិរន្តរភាព ក្នុងការផ្តល់សេវាជូនបងប្អូនពិការបានឡើយ ហើយជនពិការ ក៏គេមិនចង់រស់នៅដោយការពឹងពាក់ ឬ ដោយសារជំនួយជារៀងរហូតដែរ ប៉ុន្តែគេចង់រស់នៅដោយភាពឯករាជ្យម្ចាស់ការ ដោយផ្អែកលើសិទ្ធិរបស់គេ ។ ផ្អែកលើទស្សនៈនេះ ហើយដែលរាជរដ្ឋាភិបាលបន្តជំរុញអនុវត្តការងារកែទម្រង់ តាមគោលការណ៍អភិបាលកិច្ចល្អ ដោយផ្តល់អាទិភាពលើវិស័យរដ្ឋបាលសាធារណៈ ការប្រយុទ្ធ

ប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ រួមទាំងការរំសាយទ័ព កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិដើម្បីសន្សំសំចៃថវិការដ្ឋ ហើយបង្កើនចំណាយលើវិស័យសង្គមកិច្ច ប៉ុន្តែរាជរដ្ឋាភិបាលទទួលស្គាល់ថា ការរីកចម្រើនសេដ្ឋកិច្ចជាតិនៅមានកម្រិត ដូច្នេះជំនួយមនុស្សធម៌ក៏នៅតែជាតម្រូវការចាំបាច់តទៅទៀត/។

ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពដល់ការពង្រីកសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសាងសង់លំនៅដ្ឋាន និងធ្វើអាជីវកម្ម កសិកម្មជាគ្រួសារក្នុងក្របខ័ណ្ឌដីសម្បទាន ដើម្បីគោលដៅសង្គមកិច្ចដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ ក្នុងនោះមានជនពិការជាមុខសញ្ញាមានអាទិភាពខ្ពស់/។ ជាក់ស្តែងរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានជាច្រើនរយហិកតា នៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺជូនជនពិការប្រមាណ ៣០០ គ្រួសារ សម្រាប់សាងសង់លំនៅដ្ឋាន ធ្វើចំការ

និងមុខរបរកសិកម្មផ្សេងៗទៀត ហើយបច្ចុប្បន្ននេះ បងប្អូនមានជីវភាពរស់នៅបានធូរធារមួយកម្រិតធំ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមកោតសរសើរចំពោះ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** ដែលបានយកអស់កម្លាំងកាយចិត្ត កម្លាំងធនធាន ជួយអភិវឌ្ឍន៍ធនធានជនពិការតាមរយៈការជួយដោះស្រាយ មុខរបរជូនជនពិការបានជាច្រើនរយនាក់ ជាពិសេសជួយរកទីផ្សារលក់ផលិតផលជនពិការ ទាំងក្នុង និងក្រៅប្រទេស ដែលធ្វើឱ្យជីវភាពរស់នៅរបស់បងប្អូនបានរីកចម្រើនមួយកម្រិតធំ ហើយសង្ឃឹមថា ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** នឹងបន្តប្រពៃណីនេះ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខទៀត ហើយជនពិការជាច្រើនរយនាក់ទៀតនឹងបានទទួលផលប្រយោជន៍ពីមជ្ឈមណ្ឌលនេះ ដែលជាការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលយ៉ាងមានប្រសិទ្ធភាព។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមយកឱកាសនៃទិវាដ៏នក្ខត្តឫក្សនេះ អំពាវនាវដូចតទៅ:

១. បងប្អូនពិការទាំងអស់ ត្រូវមានសេចក្តីក្លាហានជំនឿជឿជាក់លើខ្លួនឯង ខិតខំរៀនសូត្រវិជ្ជាជីវៈ ជំនាញប្រើប្រាស់នូវសម្បទាដែលនៅមានពុះពារជំនះរាល់ការលំបាកដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន ក្នុងការចូលរួមពេញលេញ និងស្មើភាពក្នុងគ្រប់សកម្មភាពសង្គម។

២. អង្គការជាតិ និងអន្តរជាតិ សូមបន្តការអនុវត្តកម្មវិធីដែលមានស្រាប់ និងពង្រីកកម្មវិធីថ្មីបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនពិការ។

៣. គ្រប់ផ្នែក និងវិស័យទាំងអស់ ជាពិសេសរោងចក្រសហគ្រាសឯកជននិងគ្រឹះស្ថានអប់រំទាំងអស់ ត្រូវគាំទ្រដល់ការធ្វើសមាហរណកម្មជនពិការ ដោយដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងសកម្មភាពរបស់ខ្លួន ហើយបង្កលក្ខណៈឱ្យជនពិការទទួលបានការបណ្តុះបណ្តាល និងការងារធ្វើជាអតិបរមា។

៤. អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សូមបន្តជួយដល់វិស័យពិការភាព និងពិចារណាដាក់ចេញនូវគោលនយោបាយសម្រាប់វិស័យពិការភាពដោយផ្តោតលើការផ្តល់សេវាគ្រប់ផ្នែកចំពោះជនពិការ។

៥. ក្រសួង- ស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំផែនការគោលនយោបាយនិងបទដ្ឋាននានា ដើម្បីធានាសិទ្ធិជាមូលដ្ឋានក្នុងការផ្តល់ឱកាស និងការចូលរួមរបស់ជនពិការក្នុងការអភិវឌ្ឍន៍ជាតិ /។ ក្នុងន័យនេះ ត្រូវជំរុញឱ្យមានការអនុម័តច្បាប់ស្តីពីសិទ្ធិជនពិការ និងរៀបចំបទដ្ឋាន នីតិវិធីចាំបាច់នានា ដើម្បីជំរុញឱ្យមានការអនុវត្តគោលនយោបាយ និងច្បាប់ទាក់ទងនឹងជនពិការឱ្យមានប្រសិទ្ធភាពខ្ពស់/។

មុននឹងបញ្ចប់ ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរដោយស្មោះដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ បុគ្គលិកនៃ ***មជ្ឈមណ្ឌលជាតិនៃជនពិការកម្ពុជា*** បុគ្គលិក អង្គការជាតិ អន្តរជាតិ អ្នកផ្តល់ជំនួយសប្បុរសជនទាំងអស់ ដែលបានប្តេជ្ញា និងបូជាកម្លាំងកាយចិត្ត ធនធាន និងពេលវេលា ដើម្បីបំរើបុព្វហេតុពិការភាពនៅកម្ពុជា /។ ជាក់ស្តែងសមិទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ ដែលវិស័យពិការភាពទទួលបានកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្រោមការសម្របសម្រួលរបស់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយប្រកាន់ខ្ជាប់នូវទិសស្លោក ***«សង្គមមួយសម្រាប់ទាំងអស់គ្នា សង្គមមួយគ្មានឧបសគ្គរារាំងសង្គមមួយ ដែលផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន»***។

ជាទីបញ្ចប់ នាឱកាស ***បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ*** ឆ្នាំច អដ្ឋស័ក ពុទ្ធសករាជ ២៥៥០ ដែលនឹងឈានចូលមកដល់នាពេលខាងមុខនេះ ខ្ញុំមានសេចក្តីរីករាយសូមប្រសិទ្ធពរជ័យ សិរីមង្គល បវរប្រសើរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ បងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងជនពិការទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង ៥ ប្រការ គឺ***អាយុ វណ្ណៈ សុខៈ ពលៈ*** និង ***បដិភាណៈ*** កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ***